# ដើរនៅក្នុងពន្លឺ

ប្រធាន ហិនរី អាវរិង
ទីប្រឹក្សាទីមួយនៅក្នុងគណៈប្រធានទីមួយ

*អ្នកធ្វើការជ្រើសរើសជារៀងរាល់ថ្ងៃ ហើយស្ទើរតែគ្រប់ម៉ោង ដែលរក្សាអ្នកឱ្យដើរក្នុងពន្លឺ ឬងាកចេញឱ្យឆ្ងាយពីសេចក្ដីងងឹត ។*

ចំពោះយើងម្នាក់ៗ ជីវិតគឺជាការធ្វើដំណើរមួយ ។ ព្រះវរបិតាសួគ៌បានរៀបចំការធ្វើដំណើរនេះសំរាប់យើងចេញមកពីសេចក្ដីស្រឡាញ់របស់ទ្រង់ ។ យើងម្នាក់ៗមានបទពិសោធន៏ និងចរិកលក្ខណៈពិសេសដាច់ដោយឡែក ប៉ុន្តែការធ្វើដំណើររបស់យើងចាប់ផ្ដើមពីកន្លែងតែមួយ ពីមុនយើងកើតមកក្នុងពិភពលោកនេះ ។

យើងទាំងអស់គ្នាត្រូវបានបង្រៀនដោយ អិលឡូហិម ជាព្រះវរបិតានៃវិញ្ញាណរបស់យើង ។ យើងស្រឡាញ់ទ្រង់ ហើយចង់ក្លាយឱ្យដូចជាទ្រង់ជារៀងរហូត ។ ទ្រង់បានមានបន្ទូលប្រាប់យើងយ៉ាងច្បាស់នូវអ្វី ដែលនឹងតំរូវពីយើងដើម្បីឱ្យមានសេចក្ដីអំណរនោះ ។ យើងនឹងត្រូវតែទទួលរូបកាយ ព្រមជាមួយនឹងឧបសគ្គ ដែលនឹងមានចំពោះមុខ ។ យើងនឹងស្ថិតក្រោមការមានជម្ងឺ ហើយមាននៅក្នុងខ្លួនយើងនូវដំណើរការទាំងឡាយ ដែលនៅទីបំផុត នឹងនាំទៅរកសេចក្ដីស្លាប់ ។ ហើយរូបកាយរបស់យើង នឹងមាននូវការចំណង់យ៉ាងខ្លាំង ដើម្បីបំពេញខាងរាងកាយ ។

ព្រះវរបិតាសួគ៌បានពន្យល់ដល់យើងនូវអ្វី ដែលនឹងតំរូវឱ្យមាន ដើម្បីធ្វើដំណើរពីកន្លែងដែលយើងរស់នៅ រួចហើយទៅនៅជាមួយទ្រង់ជារៀងរហូត និងរស់នៅក្នុងជីវិតដែលទ្រង់រស់នៅ ។ យើងនឹងធ្វើដំណើរឆ្លងកាត់ជីវិតដោយគ្មានការចងចាំអំពីគ្រារបស់យើង ដែលបានរស់នៅជាមួយនឹងទ្រង់នៅក្នុងពិភពនៃវិញ្ញាណមុនពេលកើតទេ ។ ហើយផ្លូវតែមួយគត់ដើម្បីត្រឡប់ទៅកាន់ទ្រង់វិញ គឺយើងត្រូវតែយកឈ្នះសេចក្ដីស្លាប់ខាងរាងកាយ និងឥទ្ធិពលនៃអំពើបាបដែលនឹងកើតឡើងដោយសារតែការមិនគោរពតាមរបស់យើងចំពោះព្រះបញ្ញត្តិទាំងឡាយ ។ ទ្រង់បានប្រាប់យើងថា យើងមិនអាចយកឈ្នះលើឥទ្ធិពលនៃសេចក្ដីស្លាប់ ឬអំពើបាបដោយខ្លួនរបស់យើង--- ដោយគ្មានព្រះអង្គសង្គ្រោះរបស់យើង ដែលនឹងផ្ដាច់ចំណងនៃសេចក្ដីស្លាប់ ហើយផ្ដល់ផ្លូវមួយឱ្យយើងដើម្បីលាងស្អាតពីអំពើបាប ដែលយើងនឹងប្រព្រឹត្តជាប្រាកដនោះទេ ។

អ្នកដឹងមកពីបទគម្ពីរដែលបានបើកសម្ដែងដោយព្រះ តាមរយៈពួកព្យាការីថា មានការបះបោរមួយនៅក្នុងពិភពនៃវិញ្ញាណមុនពេលកើត នៅពេលផែនការសំរាប់ការធ្វើដំណើររបស់យើងត្រូវបានផ្ដល់ឱ្យមកយើង ។ វិញ្ញាណទាំងឡាយដែលបះបោរ មិនចង់ទទួល និងពឹងផ្អែកលើព្រះអង្គសង្គ្រោះទេ ថែមទាំងមិនចង់ប្រថុយថែមទៀតផង ដែលពួកគេអាចនឹងមិនអាចត្រឡប់ទៅព្រះវរបិតាសួគ៌ម្ដងទៀត ។ អ្នករាល់គ្នាម្នាក់ៗ បានស្ថិតនៅក្នុងចំណោមអ្នកក្លាហានស្មោះត្រង់ និងពិត ។ អ្នកបានទទួលយកព្រះអង្គសង្គ្រោះ និងផែនការសំរាប់ការធ្វើដំណើរនេះ ដើម្បីត្រឡប់ទៅកាន់សេចក្ដីអំណរនៃវត្តមានរបស់ព្រះវរបិតាសួគ៌របស់យើងវិញ ។

អ្នកអស្ចារ្យណាស់ សូម្បីតែនៅក្នុងចំណោមអ្នកទាំងឡាយដែលបានជ្រើសរើសត្រូវ នៅក្នុងការប្រកួតប្រជែងនៅក្នុងពិភពនៃវិញ្ញាណមុនពេលកើត ។ អ្នកសក្ដិសមដើម្បីមកកាន់ជីវិតរមែងស្លាប់ ហើយធ្វើដំណើរនេះនៅក្នុងគ្រាមួយ

ពេលដែលដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ មាននៅលើផែនដី។ ហើយនៅក្នុងចំណោមកូនចៅដែលរស់នៅរាប់លានរបស់ព្រះវរបិតាសួគ៌ អ្នកមានឯកសិទ្ធិដើម្បីរកឃើញនូវដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ និងសាសនាចក្រពិតរបស់ទ្រង់។ ដែលលើសពីនេះទៅទៀត ភាពពិតដែលអ្នកកំពុងតែស្តាប់នៅយប់នេះ មានន័យថាអ្នកបានជ្រើសរើសដើម្បីធ្វើដំណើរនៃជីវិតដោយដើរនៅក្នុងពន្លឺ។

កូនគ្រប់រូបរបស់ព្រះវរបិតាសួគ៌ កើតនៅក្នុងពិភពលោក គឺត្រូវបានផ្តល់ឱ្យពេលចាប់កំណើតនូវពន្លឺនៃព្រះគ្រីស្ទជាអំណោយទានដែលឥតគិតថ្លៃ។ អ្នកបានទទួលអារម្មណ៍នោះ។ វាគឺជាស្មារតីនៃការដឹងអំពីអ្វីដែលត្រូវ និងអ្វីដែលខុស និងអ្វីដែលពិត និងអ្វីដែលមិនពិត។ អ្វីទាំងនេះមានមកជាមួយអ្នកចាប់តាំងពីការធ្វើដំណើរនៅក្នុងជីវិតរបស់អ្នកបានចាប់ផ្តើម។ កត្តាដែលអ្នកបានទទួលបុណ្យជ្រមុជទឹក និងទទួលព្រះវិញ្ញាណបរិសុទ្ធ គឺជាភស្តុតាងថា អ្នកបានជ្រើសរើសដើរនៅក្នុងពន្លឺនៃព្រះគ្រីស្ទ។

នៅពេលអ្នកត្រូវបានបញ្ជាក់ជាសមាជិកមួយរូបនៃសាសនាចក្រ អ្នកត្រូវបានផ្តល់ឱ្យនូវសិទ្ធិដើម្បីមានព្រះវិញ្ញាណបរិសុទ្ធ ជាដៃគូរបស់អ្នក។ ព្រះវិញ្ញាណបរិសុទ្ធ គឺជាប្រភពពន្លឺដ៏មានអំណាចមួយ ដើម្បីស្គាល់សេចក្តីពិត ដើម្បីធ្វើតាម និងស្រឡាញ់ព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ និងដើម្បីរកឃើញផ្លូវរបស់អ្នកត្រឡប់ទៅកាន់ព្រះរបស់អ្នកវិញបន្ទាប់ពីជីវិតនេះ។

ប៉ុន្តែវិញ្ញាណដែលដឹកនាំការបះបោរនៅក្នុងពិភពលោកមុន នៅតែជំទាស់នឹងផែនការ ហើយចង់ឱ្យអ្នកវេទនា មិនអាចរកឃើញផ្លូវទៅកាន់ផ្ទះរបស់អ្នកវិញទេ។ សត្រូវនៃព្រលឹងរបស់អ្នកនោះ ស្គាល់អ្នក ហើយស្គាល់សេចក្តីល្អរបស់អ្នក។ វាដឹងថាបើវាអាចបង្វែរអ្នកឱ្យចេញពីការដើរនៅក្នុងពន្លឺ នោះវាអាចទាំងចាប់អ្នក និងបញ្ឈប់អ្នកពីការជួយអ្នកដទៃនៅលើផ្លូវធ្វើដំណើរ។ វាស្គាល់ថាអ្នកល្អប៉ុណ្ណា និងអំណាចរបស់អ្នកដើម្បីបង្រៀន និងមានឥទ្ធិពលចំពោះកូនចៅរបស់ព្រះវរបិតាសួគ៌រាប់រយនាក់នៅក្នុងជីវិតនេះ---ហើយមនុស្សរាប់ពាន់នាក់ទៀត ដែលនឹងដើរតាមផ្លូវរបស់អ្នក។ បើវាអាចឱ្យអ្នកវង្វេងចេញពីពន្លឺនៃការធ្វើដំណើររបស់អ្នក នោះវាអាចធ្វើឱ្យមនុស្សជាច្រើនអន្តរាយ និងវេទនា។

កត្តាដែលអ្នកកំពុងតែស្តាប់ឥឡូវនេះ គឺជាភស្តុតាងថាព្រះទទួលស្គាល់នូវសារៈសំខាន់ដ៏មហិមារបស់អ្នក ហើយថាអ្នកបានជ្រើសរើសដើរនៅក្នុងពន្លឺដែលទ្រង់បានប្រទានដល់អ្នក។ ការជ្រើសរើសទាំងនោះ មិនងាយស្រួលដើម្បីមើលឃើញច្បាស់ជានិច្ចនោះទេ។ អ្នកធ្វើការជ្រើសរើសជារៀងរាល់ថ្ងៃ ហើយស្ទើរតែគ្រប់ម៉ោង ដែលអាចរក្សាអ្នកឱ្យដើរក្នុងពន្លឺ ឬបង្វែរអ្នកចេញទៅកាន់សេចក្តីងងឹត។ ការជ្រើសរើសសំខាន់បំផុត គឺអំពីអ្វីដែលអ្នកដាក់ដួងចិត្តរបស់អ្នកទៅលើ។

មានរឿងជាច្រើនណាស់ ដែលអ្នកអាចពិចារណាថាជាអ្វីដែលគួរឱ្យប្រាថ្នា។ ឧទាហរណ៍ថា នៅត្រង់កំរិតណាមួយនោះ យើងទាំងអស់គ្នាចង់បានការស្រុះស្រួលពីអ្នកដទៃ។ យើងទាំងអស់គ្នាមានអារម្មណ៍ថាត្រូវការមិត្តភក្តិច្រើន។ យើងទាំងអស់គ្នាកំពុងតែស្រាវជ្រាវរកភស្តុតាងខ្លះៗ ដែលថាយើងគឺជាមនុស្សមានតម្លៃ។ យើងបានធ្វើការជ្រើសរើសដោយផ្អែកទៅលើបំណងប្រាថ្នាទាំងនោះ។ បំណងប្រាថ្នាខ្លះអាចនាំយើងឱ្យឃ្លាតឆ្ងាយពីពន្លឺ ដែលព្រះបានប្រទានដល់យើងដើម្បីធ្វើជាការដឹកនាំ។ បំណងប្រាថ្នាខ្លះអាចបំភ្លឺពន្លឺនោះឡើង ដែលយើងអាចខរកឃើញផ្លូវរបស់យើង។

នៅពេលខ្ញុំក្រឡេកមើលក្រោយវិញ ខ្ញុំដឹងថាខ្ញុំមិនបានដឹងអំពីសារៈសំខាន់នៃការជ្រើសរើសទាំងនោះទេ។ ខ្ញុំចង់ក្លាយជាមនុស្សដែលជំរើសចូលក្នុងក្រុមអត្តពលកម្ម។ ខ្ញុំចង់រៀនពូកែនៅក្នុងសាលា។ ខ្ញុំចង់ស្វែងរកមិត្តល្អ និងមិត្ត

ពិត។ នៅពេលខ្ញុំធ្វើការជ្រើសរើសដែលចេញមកពីសេចក្ដីប្រាថ្នាទាំងនោះ ខ្ញុំកាន់តែដឹងថា ខ្ញុំអាចនឹងឃ្លាតឆ្ងាយចេញពីពន្លឺ ឬក៏ឆ្ពោះទៅរកពន្លឺ។

ភាពជោគជ័យមួយចំនួនរបស់ខ្ញុំ និងមិត្តភក្ដិមួយចំនួនរបស់ខ្ញុំ គឺជាកត្តាចំបងនៅក្នុងពន្លឺស្មារតីយល់ដឹងរបស់ខ្ញុំ។ លើសពីអ្វីដែលខ្ញុំបានដឹងនៅពេលនោះ អ្វីផ្សេងទៀតគឺកំពុងតែនាំខ្ញុំចេញពីពន្លឺបន្តិចម្ដងៗ។ នៅលើផ្លូវវែងឆ្ងាយ និងសំខាន់ ការជ្រើសរើសទាំងឡាយដែលខ្ញុំបានធ្វើដើម្បីបំពេញតាមបំណងប្រាថ្នារបស់ខ្ញុំសំរាប់ភាពជាដៃគូ និងទទួលអារម្មណ៍ថាមានការទទួលស្គាល់នោះ កំពុងតែនាំខ្ញុំឆ្ពោះទៅ ឬទាញខ្ញុំចេញពីពន្លឺដែលដឹកនាំផ្លូវរបស់ខ្ញុំ។

អស់រយៈកាលជាយូរមក ព្រះវរបិតាសួគ៌តាមរយៈពួកព្យាការីរបស់ទ្រង់ បានប្រទានដល់យើងនូវមធ្យោបាយមួយ ដើម្បីដឹងថាតើការជ្រើសរើសណាមួយដែលសំខាន់បំផុត ហើយហេតុអ្វី---និងរបៀបដើម្បីធ្វើការសំរេចចិត្តនោះ។

ការសង្ខេបដ៏ល្អបំផុតដែលខ្ញុំដឹង គឺនៅក្នុងពាក្យសំដីចេញពីមរ៉ូណៃ នៅពេលដែលលោកដកស្រង់ពាក្យសំដីឪពុកលោក លោកមរមន។ ខ្ញុំប្រាថ្នាថាខ្ញុំយល់ពាក្យនេះបានល្អកាលពីខ្ញុំនៅវ័យក្មេងដូចជាអ្នក ដូច្នេះខ្ញុំសូមអធិស្ឋានថាព្រះអម្ចាស់នឹងនាំយកពាក្យទាំងនោះ ដាក់ចូលក្នុងដួងចិត្តរបស់អ្នក។

"ប៉ុន្តែមើលចុះ អ្វីដែលមកពីព្រះ អញ្ជើញហើយញុះញង់ឱ្យធ្វើល្អឥតឈប់ឈរ ហេតុដូច្នោះហើយ អ្វីក៏ដោយដែលអញ្ជើញ ហើយញុះញង់ឱ្យធ្វើល្អ ហើយឱ្យស្រឡាញ់ព្រះ ហើយឱ្យបំរើទ្រង់គឺផុសគំនិតមកពីព្រះ។

"ហេតុដូច្នោះហើយ ចូរប្រយ័ត្នចុះ---ដើម្បីកុំឱ្យអ្នករាល់គ្នាវិនិច្ឆ័យថាអ្វីដែលអាក្រក់ នោះមកពីព្រះឡើយ ឬក៏ថាអ្វីដែលល្អមកពីព្រះទុកជាមកពីអារក្សឡើយ។

"ត្បិតមើលចុះ ឱបងប្អូនរបស់ខ្ញុំអើយ ត្រូវបានប្រទានដល់អ្នករាល់គ្នាឱ្យវិនិច្ឆ័យ ដើម្បីឱ្យអ្នកដឹងខុស និងត្រូវ ហើយវិធីវិនិច្ឆ័យ នោះច្បាស់លាស់ដើម្បីឱ្យអ្នករាល់គ្នាអាចដឹងដោយងឹរះដ៏ឥតខ្ចោះ ហាក់បីដូចជាពន្លឺថ្ងៃពីយប់ងងឹត"។1

បទគម្ពីរបង្រៀនដល់យើងនូវប្រភព និងអំណាចនៃពន្លឺ។

"ត្បិតមើលចុះ ព្រះវិញ្ញាណនៃព្រះគ្រីស្ទ ត្រូវបានប្រទានដល់មនុស្សគ្រប់រូប ដើម្បីឱ្យគេអាចដឹងខុស និងត្រូវ ហេតុដូច្នោះហើយ ខ្ញុំបង្ហាញដល់អ្នកនូវវិធីវិនិច្ឆ័យ ត្បិតគ្រប់ទាំងអ្វីៗដែលអញ្ជើញឱ្យធ្វើល្អ ហើយដែលបញ្ចុះបញ្ចូលឱ្យជឿដល់ព្រះគ្រីស្ទ នោះគឺបានចាត់មកពីព្រះចេស្ដា និងអំណោយទាននៃព្រះគ្រីស្ទ ហេតុដូច្នេះហើយ អ្នករាល់គ្នាអាចដឹងដោយតំរិះដ៏ឥតខ្ចោះថាមកពីព្រះ។

"ប៉ុន្តែ អ្វីៗដែលបញ្ចុះបញ្ចូលឱ្យមនុស្សធ្វើអាក្រក់ ហើយមិនឱ្យជឿដល់ព្រះគ្រីស្ទ ហើបដិសេធទ្រង់ ហើយមិនបំរើព្រះទេ នោះអ្នករាល់គ្នាអាចដឹងដោយតំរិះដ៏ឥតខ្ចោះថា មកពីអារក្ស ត្បិតតាមរបៀបនេះហើយដែលអារក្សប្រព្រឹត្ត ត្បិតវាមិនដែលបញ្ចុះបញ្ចូលមនុស្សឱ្យធ្វើល្អឡើយ មិនដែលទេ សូម្បីតែមួយក៏គ្មានសោះឡើយ ហើយពួកទេវតាវាក៏មិនដែលដែរ ហើយពួកដែលស្ដាប់បង្គាប់វាក៏មិនដែលដែរ"។2

ឥឡូវនេះខ្ញុំអាចមើលឃើញបានល្អជាងកាលពីនៅក្មេង នូវរបៀបដែលខ្ញុំអាចប្រើប្រាស់នូវការដឹកនាំនោះ។ មានក្រុមកីឡាមួយ ដែលមានពួកកីឡាករ និងពួកគ្រូបង្វឹក ដែលជះឥទ្ធិពលមកលើខ្ញុំឱ្យធ្វើល្អ។ មានមួយចំនួនទៀតមិនដូច្នោះទេ។ ខ្ញុំមានពួកមិត្តភក្ដិមួយចំនួន ដែលពួកគេមិនមែនជាសមាជិកនៃសាសនាចក្រនៃ ព្រះយេស៊ូវគ្រីស្ទទេ តាមរយៈគំរូរបស់ពួកគេបានជះឥទ្ធិពលមកលើខ្ញុំឱ្យធ្វើល្អ ហើយចងចាំព្រះអង្គសង្គ្រោះ។

មានមិត្តរួមសាលា និងគ្រូបង្រៀនជាច្រើនដែលស្រុះស្រួល និងមានមិត្តភាពដែលខ្ញុំបានស្វែងរកឃើញ ជាមនុស្សដែលបានធ្វើឱ្យខ្ញុំចង់ធ្វើល្អ ហើយបង្កើនអារម្មណ៍របស់ខ្ញុំចំពោះព្រះអង្គសង្គ្រោះ។ ខ្ញុំត្រូវបានប្រទានពរឱ្យរកឃើញផ្លូវរបស់ខ្ញុំ។ ប៉ុន្តែខ្ញុំនឹងបានធ្វើល្អជាងនេះ បើខ្ញុំយល់ដឹងអំពីសារៈសំខាន់នៃការជ្រើសរើសរបស់ខ្ញុំ និងរបៀបដើម្បីជ្រើសរើស។

មរមនបានដឹងអំពីរឿងនេះ។ ខ្ញុំបានអានកាន់តែយកចិត្តទុកដាក់នូវពាក្យរបស់គាត់នៅក្នុងព្រះគម្ពីរមរមន និងគម្ពីរផ្សេងទៀតដូចនេះ។ ខ្ញុំនឹងត្រូវបានប្រទានពរជ័យច្រើន និងការការពារថែមទៀត។ នេះគឺជាពាក្យរបស់មរមនៈ

"ដោយឃើញថាអ្នករាល់គ្នាស្គាល់នូវពន្លឺដែលអ្នករាល់គ្នាអាចយកទៅវិនិច្ឆ័យ ឯពន្លឺនោះគឺជាពន្លឺនៃព្រះគ្រីស្ទ នោះចូរឱ្យឃើញថា អ្នករាល់គ្នាមិនវិនិច្ឆ័យដោយខុសឆ្គងឡើយ ត្បិតដោយការវិនិច្ឆ័យដដែលនេះហើយ ដែលអ្នករាល់គ្នានឹងត្រូវបានវិនិច្ឆ័យវិញ។

"ហេតុដូច្នោះ... ឱបងប្អូនអើយ ខ្ញុំសូមអង្វរដល់អ្នករាល់គ្នាថា អ្នករាល់គ្នាត្រូវព្យាយាមស្វែងរកនៅក្នុងពន្លឺ នៃព្រះគ្រីស្ទ ដើម្បីឱ្យអ្នករាល់គ្នាអាចដឹងខុស និងត្រូវ ហើយបើសិនជាអ្នករាល់គ្នាក្ដាប់ជាប់នូវគ្រប់ទាំងអ្វីៗដែលល្អ ហើយមិនកាត់ទោសរបស់ទាំងនោះទេ នោះអ្នកប្រាកដជាកូននៃព្រះគ្រីស្ទមែន។

"ហើយឥឡូវនេះ... ឱបងប្អូនរបស់ខ្ញុំអើយ ធ្វើម្ដេចឱ្យអ្នករាល់គ្នាមានលទ្ធភាព ហើយក្ដាប់ជាប់នូវគ្រប់ទាំងអ្វីៗដែលល្អបាន?" 3

គឺដោយសារសេចក្ដីជំនឿដែលអ្នកអាចក្ដាប់ជាប់នូវគ្រប់ទាំងអ្វីៗដែលល្អ។ ខ្ញុំអធិស្ឋានដោយអស់ពីដួងចិត្តរបស់ខ្ញុំថាសេចក្ដីជំនឿរបស់អ្នកនឹងត្រូវបានបង្កើនឡើង ថាអ្នកគឺជាបុត្ររបស់ព្រះជាទីស្រឡាញ់។ ខ្ញុំសូមធ្វើទីបន្ទាល់ចំពោះអ្នករាល់គ្នាថា អ្នកធ្លាប់ជាជនម្នាក់ក្នុងចំណោមពួកអ្នកក្លាហាន ដើម្បីឈោងដល់ចំនុចមួយដែល ឥឡូវអ្នកកំពុងតែនៅក្នុងការធ្វើដំណើរនៃជីវិតនេះ។ ដូចដែលអ្នកត្រូវបានគូសចំណាំ ជាគោលដៅមួយដោយសត្រូវនៃសេចក្ដីសុចរិត អ្នកត្រូវបានការពារ និងមើលថែដោយព្រះវរបិតាសួគ៌របស់អ្នក និងព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ។ ពួកទ្រង់ស្គាល់អ្នក។ ពួកទ្រង់ស្គាល់កម្លាំងទាំងអស់ និងបុគ្គលម្នាក់ៗដែលនៅជុំវិញអ្នក។ ពួកទ្រង់ដឹងនូវអ្វីដែលនៅពីខាងមុខអ្នក។ ហើយហេតុដូច្នេះពួកទ្រង់ស្គាល់ថាការជ្រើសរើសណា ដែលអ្នកធ្វើ សេចក្ដីប្រាថ្នាណាដែលអ្នកសម្រេចចិត្តចង់បាន និងកាលៈទេសៈណាខ្លះដែលនៅជុំវិញអ្នក ដែលអ្នកនឹងធ្វើឱ្យមានភាពខុសគ្នាបំផុត នៅក្នុងការរក្សាអ្នកឱ្យដើរនៅក្នុងពន្លឺ។ ខ្ញុំសូមធ្វើទីបន្ទាល់ថាដោយសារព្រះវិញ្ញាណនៃព្រះគ្រីស្ទ និងដោយសារព្រះវិញ្ញាណបរិសុទ្ធ អ្នកអាចដើរដោយមានទំនុកចិត្តនៅក្នុងការលំបាកអ្វីក៏ដោយដែលនឹងមានមក។ ដោយសារអ្នកមានតម្លៃយ៉ាងខ្លាំង ការសាកល្បងមួយចំនួនរបស់អ្នកអាចនឹងធ្ងន់ធ្ងរ។ អ្នកមិនចាំបាច់បាក់ទឹកចិត្ត និងភ័យខ្លាចនោះទេ។ ផ្លូវឆ្លងកាត់ការលំបាកទាំងឡាយ តែងតែត្រូវបានរៀបចំសំរាប់អ្នក ហើយអ្នកនឹងរកឃើញផ្លូវនោះ បើអ្នកអនុវត្តសេចក្ដីជំនឿរបស់អ្នក។

អ្នកត្រូវតែមានសេចក្ដីជំនឿដើម្បីអធិស្ឋាន។ អ្នកត្រូវតែមានសេចក្ដីជំនឿដើម្បីពិចារណាអំពីព្រះបន្ទូលរបស់ព្រះ។ អ្នកត្រូវតែមានសេចក្ដីជំនឿដើម្បីធ្វើរឿងទាំងនោះ ហើយទៅកន្លែងទាំងនោះ ដែលអញ្ជើញឱ្យមានព្រះវិញ្ញាណនៃព្រះគ្រីស្ទ និងព្រះវិញ្ញាណបរិសុទ្ធ។

ខ្ញុំសន្យានឹងអ្នកថានៅក្នុងអំឡុងពីរបីថ្ងៃបន្ទាប់ អ្នកនឹងទទួលនូវអារម្មណ៍ពន្លឺនៃព្រះវិញ្ញាណនៃព្រះគ្រីស្ទ និងព្រះវិញ្ញាណបរិសុទ្ធនៅក្នុងជីវិតរាល់ថ្ងៃរបស់អ្នក។ នៅពេលអ្នកដើរនៅក្នុងពន្លឺ អ្នកនឹងទទួលបានអារម្មណ៍កក់ក្ដៅ និង

សុភមង្គលខ្លះៗ ដែលនឹងទីបំផុតនឹងជារបស់អ្នក នៅពេលអ្នកត្រូវបានស្វាគមន៍ក្នុងការត្រឡប់មកផ្ទះវិញ ជាមួយនឹងមនុស្សរាប់រយនាក់ ហើយប្រហែលជារាប់ពាន់នាក់ដទៃទៀត ដែលអ្នកនឹងនាំមកជាមួយអ្នក ដែលបានដើរនៅក្នុងពន្លឺ ដោយសារតែអ្នកបានដើរនៅក្នុងពន្លឺ។

នេះគឺជាសាសនាចក្រពិតនៃ ព្រះយេស៊ូវគ្រីស្ទ។ មានព្យាការីនៅរស់ គឺព្យាការីថូម៉ាស អេស ម៉នសុន។ ហើយមានទាំងពួកអ្នកបំរើពិត និងពួកទេវតាជួយអ្នកនៅលើផ្លូវ។ ខ្ញុំសូមថ្លែងទីបន្ទាល់ដូច្នេះនៅក្នុងព្រះនាមដ៏ពិសិដ្ឋនៃព្រះ-យេស៊ូវគ្រីស្ទ អាម៉ែន។

កំណត់ចំណាំ

1. មរ៉ូណៃ 7:13--15។
2. មរ៉ូណៃ 7:16--17។
3. មរ៉ូណៃ 7:18--20។